# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅព្រះសហគមន៍សន្តីម៉ារី
# តួតាំង ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២០
# យើងរស់នៅក្រោមព្រះពន្លឺរបស់ព្រះគ្រីស្ត

**អត្ថបទទី១៖ ម៉ាឡាគី ៣,១-៤**

ព្រះអង្គនឹងគង់កាត់ក្តី ដូចជាងទងអង្គុយ រំលាយ និងបន្សុទ្ធសាច់ប្រាក់។ ព្រះអង្គនឹងជម្រះកូនចៅលេវីឲ្យបានបរិសុទ្ធ ព្រះអង្គនឹងបន្សុទ្ធពួកគេ ដូចបន្សុទ្ធមាស និងប្រាក់។ មគ ៣,៣

**អត្ថបទទី២៖ ហេប្រឺ ២,១៤-១៨**

ដោយព្រះអង្គផ្ទាល់បានរងទុក្ខលំបាក នៅពេលជួបការល្បួងល ព្រះអង្គក៏អាចជួយអស់អ្នកដែលជួបនឹងការល្បួងលបានដែរ។ ហាប ២,១៨

**ដំណឹងល្អ៖ លូកា ២,២២-៤០**

លោកតាស៊ីម្មូនក៏យកព្រះឱរសមកបី រួចសរសើរតម្កើងព្រះជាម្ចាស់។ លក ២,២៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះជាឱកាសមួយ ដើម្បីសួរសុខទុក្ខនិងដើម្បីណែនាំព្រះពរដល់បងប្អូនទាំងអស់ នៅថ្ងៃដែលលោកយ៉ូសែបនិងព្រះនាងម៉ារី បានថ្វាយព្រះឱរសយេស៊ូនៅក្នុងព្រះវិហារទីក្រុងយេរ៉ូសាឡឹម។ ថ្ងៃនេះ ដែលយើងគោរពព្រះគ្រីស្តដែលជាព្រះពន្លឺ លោកតាស៊ីម៉ូន យាយហាណ្ណា បានឃើញព្រះយេស៊ូជាពន្លឺដែលមកបំភ្លឺប្រជារាស្ត្រទាំងឡាយ។ ជីវិតរបស់យើង យើងបានទទួលពន្លឺពីព្រះយេស៊ូដើម្បីណែនាំឲ្យជីវិតរបស់យើងមានផ្លាយ៉ាងច្រើន។ អ្វីដែលសំខាន់បំផុត គឺជំនឿដែលយើងបានទទួលពីព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់យើង ថ្ងៃនេះយើងមានចំណុចច្រើនដែលណែនាំឲ្យយើងត្រូវតែពោរពេញដោយអំណរសប្បាយ។ លោកតាស៊ីម៉ូន និងយាយហាណ្ណាបានមើលយ៉ាងច្បាស់ គឺព្រះយេស៊ូជាព្រះសង្គ្រោះនិងជាព្រះពន្លឺដើម្បីបំភ្លឺពិភពលោក។

ព្រះវិហារនៅទីក្រុងយេរ៉ូសាឡឹមធំណាស់ ថ្ងៃដែលគេធ្វើបុណ្យថ្វាយព្រះឱរសយេស៊ូនៅក្នុងព្រះវិហារនេះ ជាថ្ងៃដែលមានមនុស្សយ៉ាងច្រើនដែលមកដើម្បីថ្វាយកូនរបស់គេទៅព្រះជាម្ចាស់។ ដូច្នេះ ព្រះនាងម៉ារីនិងលោកយ៉ូសែបដូចឪពុកម្តាយយ៉ាងច្រើនដែលមកថ្ងៃនោះដែរ ហើយព្រះឱរសយេស៊ូក៏ដូចជាកូនង៉ែតដែលឪពុកម្តាយយកមកថ្វាយព្រះជាម្ចាស់ដែរ។ ប៉ុន្តែ លោកតាស៊ីម៉ូននិងយាយហាណ្ណា នៅក្នុងចំណោមទារកយ៉ាងច្រើនគេមើលឃើញព្រះយេស៊ូតែម្នាក់ គេដឹងនេះជាព្រះយេស៊ូ នេះជាព្រះនាងម៉ារី នេះជាលោកយ៉ូសែប។ ព្រះនាងម៉ារីនិងលោកយ៉ូសែបមានសម្លៀកបំពាក់ដូចប្រជាជនទូទៅ និងព្រះឱរសយេស៊ូដូចកូនង៉ែតផ្សេងទៀត ប៉ុន្តែលោកតាស៊ីម៉ូននិងយាយហាណ្ណាគេមើលឃើញនៅក្នុងមហាជន គេដឹងនេះជាព្រះពន្លឺដែលមកបំភ្លឺពិភព

លោក។ **តើយើងចេះមើលឃើញវត្តមានរបស់ព្រះយេស៊ូនៅក្នុងជីវិតយើង នៅក្នុងសង្គមបច្ចុប្បន្ននេះឬទេ?** ហោរាចារ្យពីដើម គេបានធ្វើដំណើរពីចម្ងាយគេមើលឃើញព្រះយេស៊ូនៅក្នុងក្រោលគោនាភូមិបេថ្លេហឹម លោកតាស៊ីម៉ូននិងយាយហាណ្ណាក៏ដូចគ្នាដែរ គេបានមើលឃើញព្រះយេស៊ូនៅក្នុងចំណោមកូនង៉ែតយ៉ាងច្រើន ដូច្នេះនៅក្នុងជីវិតរបស់យើង យើងធ្វើដូចម្ដេចដើម្បីមើលឃើញព្រះយេស៊ូដែលកំពុងមានវត្តមាន ដែលកំពុងមានព្រះជន្ម ដែលកំពុងគង់នៅជាមួយយើង។

ឲ្យយើងគិតផ្ទាល់ខ្លួន នៅពេលយើងទៅផ្សារ ទៅសាលា ទៅធ្វើការ... **តើយើងមើលឃើញវត្តមានរបស់ព្រះយេស៊ូឬទេ?** នៅពេលយើងមើលបងប្អូនដ៏តូចតាចម្នាក់គឺព្រះយេស៊ូហើយ ដូច្នេះឲ្យយើងបើកភ្នែកមើលអ្នកជំងឺ អ្នកគ្មានទីពឹង អ្នកសុំទាន... អ្នកទាំងនេះហើយជាព្រះយេស៊ូ សូមឲ្យយើងចេះមើលឃើញ។ ពេលយើងមើលឃើញព្រះយេស៊ូហើយ ឲ្យយើងចេះទទួលកម្លាំងពេលយើងចូលព្រះវិហារ យើងទទួលព្រះកាយ យើងស្ដាប់ព្រះបន្ទូល ជាព្រះយេស៊ូផ្ទាល់ដែលមកបំភ្លឺជីវិតយើង ដើម្បីឲ្យយើងមានសេចក្ដីក្លាហាន។ ថ្ងៃនេះ គេលុបចោលកម្មវិធីជាមួយអ្នកជាប់ក្នុងមន្ទីរឃុំឃាំងនៅកំពង់សោមដោយសារគេខ្លាចជំងឺកូវីដ១៩ នេះណែនាំឲ្យយើងមានជំងឺមួយទៀតគឺជំងឺភ័យខ្លាច។ យើងមានព្រះយេស៊ូគ្រីស្ដដែលគង់នៅជាមួយយើង កុំឲ្យយើងភ័យខ្លាចហួសហេតុ យើងដឹងថាយើងជាគ្រីស្ដបរិស័ទនៅក្នុងជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ ឲ្យយើងមានសេចក្ដីក្លាហានដើម្បីផ្ដល់សក្ខីភាពអំពីវត្តមានរបស់ព្រះយេស៊ូ។

**តើខ្ញុំផ្ទាល់ខ្លួនខ្ញុំទៅជាវត្តមានរបស់ព្រះយេស៊ូរបៀបណាសម្រាប់បងប្អូនឯទៀតៗ? តើយើងផ្ដល់សក្ខីភាពរបៀបណាដល់បងប្អូនឯទៀតៗ?** នៅក្នុងគម្ពីរ យើងត្រូវគេបៀតបៀន គេជំទាស់ គេអន់ចិត្តជាមួយបងប្អូនដែលដើរតាមព្រះយេស៊ូ។ យើងដឹងថា មានខ្លះគេមើលងាយ មានខ្លះគេរិះគន់ មានខ្លះគេអន់ចិត្តជាមួយសាវ័ករបស់ព្រះគ្រីស្ដរហូតដល់បច្ចុប្បន្ននេះ។ ប៉ុន្តែ នៅក្នុងជំនឿដែលយើងទទួលពីព្រះយេស៊ូដែលជាព្រះសង្គ្រោះ ជាព្រះពន្លឺ យើងពោរពេញដោយសេចក្ដីក្លាហានដើម្បីផ្ដល់សក្ខីភាព ឲ្យគេឃើញវត្តមានរបស់ព្រះគ្រីស្ដតាមរយៈជីវិតរបស់យើង ដែលចេះស្រឡាញ់គ្នាទៅវិញទៅមក។ យើងធ្វើដូចម្ដេច ដើម្បីឲ្យយើងទៅជាគ្រួសារមួយដែលចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ធ្វើដំណើរជាមួយគ្នា ដើម្បីបង្ហាញវត្តមានរបស់ព្រះយេស៊ូនៅក្នុងជីវិតរបស់យើង។

ថ្ងៃនេះយើងអធិដ្ឋាន ដើម្បីឲ្យបងប្អូនទាំងអស់ចម្រើនពរនៅក្នុងឆ្នាំថ្មី ចម្រើនសុខភាព ចម្រើនកម្លាំងកាយកម្លាំងចិត្ត និងមានជំនឿរឹងមាំ ដើម្បីឲ្យឆ្នាំថ្មីនេះទៅជាឆ្នាំដែលយើងត្រូវតែមានសេចក្ដីក្លាហាន។ ឆ្នាំនេះឲ្យយើងមានកម្លាំង សេចក្ដីក្លាហានប្រកាសដំណឹងល្អ ដើម្បីឲ្យ

យើងទទួលព្រះពរពីព្រះជាម្ចាស់ពីមួយថ្ងៃទៅមួយថ្ងៃ។ ឲ្យយើងរស់ក្រោមព្រះពន្លឺរបស់ព្រះអង្គ ណែនាំឲ្យជីវិតរបស់យើងមានផ្កាយ៉ាងស្អាត កុំឲ្យជីវិតរបស់យើងទៅជាជីវិតអសកម្ម ឲ្យយើងមានផ្លែនៃសេចក្ដីសុខ សេចក្ដីស្រឡាញ់ អំណរ និងសេចក្ដីសង្ឃឹម។ សូមព្រះជាម្ចាស់ប្រទានព្រះពរ ដើម្បីឲ្យឆ្នាំថ្មីនេះទៅជាឆ្នាំដ៏សុខសាន្តសម្រាប់បងប្អូនទាំងអស់។ អាម៉ែន៕